**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កិច្ចព្រមព្រៀង រវាងនាយកក្រុមហ៊ុន យូ នី ប្រូស (ខេមបូឌា) អូអិលធីឌី ជាមួយ តំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុម ប្រចាំក្រុមហ៊ុន

ឆ្នាំពីរពាន់ម្ភៃបី ខែមិថុនា ថ្ងៃទីដប់បួន វេលាម៉ោងដប់ព្រឹកនៅការិយាល័យក្រុមហ៊ុន**យូនីប្រូស**(**ខេមបូឌា**)**អូអិលធីឌី** មានកិច្ចប្រជុំពិភាក្សា រវាងនាយកក្រុមហ៊ុន ជាមួយតំណាងកម្មករប្រតិភូបុគ្គលិក និងប្រធានក្រុមប្រចាំក្រុមហ៊ុនស្តីពីការព្យួរកិច្ចសន្យាការងារក្រោយពីបានពិភាក្សាគ្នារួចមក ភាគីទាំងពីរបានព្រមព្រៀងគ្នាដូច ខាងក្រោម ៖

១.បច្ចុប្បន្ននៃក្រុមហ៊ុនដែលខ្វះអ្នកបញ្ជាទិញដែលបណ្តាលអោយសង្វាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ ហេតុដូចនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន២៨៦នាក់(ស្រី១៧៩នាក់)ក្នុងចំណោមកម្មករនិយោជិតសរុប ២៨៩នាក់ (ស្រី១៧៩នាក់) រយៈពេល ៦១ថ្ងៃដោយគិតចាប់ពី ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣ រហូតដល់ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។

២.ភាគីទាំងពីរយល់ព្រមទទួលយកនិងផ្តល់ប្រាក់ឧបត្ថមចំនួន៣០ដុល្លាអាមេរិកក្នុងមួយខែ(បូករួមទាំងប្រាក់ធ្វើដំណើរនិងប្រាក់អត្ថប្រយោជន៍ផ្សេងៗ) សម្រាប់កម្មករ ម្នាក់ៗ ក្នុងរយៈ ពេលព្យួរការងារនេះ ។

៣.ក្នុងករណីបងប្អូនកម្មករ មិនបានចូលធ្វើការវិញតាមការកំណត់នេះទេ ក្រុមហ៊ុននឹងអនុវត្តតាម ច្បាប់ស្តីពីការងារ និងបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន។

ប្រាក់ឧបត្ថមក្នុងកំឡុងពេលព្យួរកិច្ចសន្យានេះនឹងបើកជូនបងប្អូនកម្មករនិយោជិកនៅថ្ងៃទី១០ខែកក្កដាឆ្នាំ ២០២៣ ។

អង្គប្រជុំបានចប់នៅវេលាម៉ោង១០ និង៣០នាទីព្រឹក នាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោគយល់សហការគ្នាយ៉ាងរលូន។

ថ្ងៃពុធ ១១រោច ខែជេស្ឋ ឆ្នាំថោះ ចត្វាស័ក ព.ស ២៥៦៧
រាជធានីភ្នំពេញ ថ្ងៃទី 14 ខែ មិថុនា ឆ្នាំ2023
នាយកក្រុមហ៊ុន

UNIPROS (CAMBODIA) ENTERPRISE CO., LTD.
人事专用章
Huang Ming Zhong

ស្នាមមេដៃតំណាងកម្មករនិយោជិត

ឈៀវ លៀងអេង ឈួន ចាន់រី សៅ សាវ៉ាន់ ឌុល ខ្សែសីន

ស្នាមមេដៃតំណាងកម្មករនិយោជិត

ហួន ថា ប្រាក់ ស្រីនី សែម និមុល មឿន ស្រីមុំ សន ចិត្រា ជួន រដ្ឋា ស៊ូ សុគា